**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

**សំណុំរឿងព្រហ្មទណ្ឌ**

**លេខ : ៣៩២**

**ចុះថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០២៣**

**សាលក្រមព្រហ្មទណ្ឌ**

**លេខ : ២៥ "គ"**

**ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៤**

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ដោយមានសមាសភាពដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ជាចៅក្រមប្រឹក្សា

លោកស្រី ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង។

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩២ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុខគាង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅមុនពេលឃាត់ខ្លួននៅភូ[redacted] ខេត្តកំពង់ឆ្នាំង, ឪពុកឈ្មោះ [redacted] វ៉ាន់ថាន់ "រ" ម្តាយឈ្មោះ[redacted]សារ៉ុម "រ" នៅលើវ ជាអនីតិជន ទោសពីមុន គ្មាន ។ ( ឃុំខ្លួននៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២៣)

ជាប់ចោទពីបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ និងថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] ប៊ុនសុជា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅមុនពេលឃាត់ខ្លួននៅភូ[redacted] ខេត្តកំពង់ឆ្នាំង, ឪពុកឈ្មោះ[redacted] ប៊ុនប៉ា "ស" ម្តាយឈ្មោះ [redacted]រុធនី "រ" នៅលើវ ជានីតិជន ទោសពីមុន គ្មាន ។ ( ក្រៅឃុំ)

ជាប់ចោទពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និង មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ណារី ភេទ ស្រី អាយុ ៥១ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅ[redacted]



Scanned with CamScanner

[redacted] ខេត្តកំពង់ឆ្នាំង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីម ភេទ ប្រុស អាយុ ៣៥ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិជើងខ្នារ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខគាង ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុខជា ។

-បានឃើញ របាយការណ៍សំយោគលេខ ៦៣/២៣ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧១ ជ.ស.ព/២៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៨១ ចុះថ្ងៃទី០៨ ខែ សីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ។

-បានឃើញ ដីកាចាត់តាំងចៅក្រមក្រុមប្រឹក្សាជំនុំជម្រះលេខ ៤២៤ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

-បានឃើញ ឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

## អង្គហេតុនៃរឿងមានដូចតទៅ ÷

កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ នៅចំណុចផ្សារពន្លៃ ស្ថិតនៅភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ឈ្មោះ [redacted] សុខគាង ភេទប្រុស អាយុ ១៧ឆ្នាំ បានផ្តោះទ្វារចូលតូបលក់ដូររបស់អាជីវករលក់ដូរឈ្មោះ [redacted] ណារី និងឈ្មោះ [redacted] សារីម នៅផ្សារពន្លៃ ហើយបានលួចយកខាវ៉ាប៉ាវ ០៣កេស ,ទឹកដោះគោឃុន ០៥កេស បារីអូរី ០១ស៊ុង ,បារី ៥៥៥ ០១ស៊ុង ,ថង់ ០២ការ៉ុង ,ស្លាបព្រា ០១ការ៉ុងតូច ,ចង្កឹះ ០១ការ៉ុងតូច ពេលលួចបានឈ្មោះ [redacted] សុខគាង បានយកឥវ៉ាន់ទាំងនោះទៅលក់ឱ្យឈ្មោះ [redacted] ប៊ុនសុជា ។ លុះដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០២៣ វេលាម៉ោង ១០យប់ ឈ្មោះ [redacted] សុខគាង បានចូលទៅលួចឥវ៉ាន់នៅក្នុងផ្សារពន្លៃម្តងទៀត តែត្រូវម្ចាស់គេមកទាន់ និងប្តឹងសមត្ថកិច្ចឱ្យធ្វើការចាប់ខ្លួនឈ្មោះ [redacted] សុខគាង តែម្តង ។ បន្ទាប់ពីសាកសួររួចសមត្ថកិច្ចបន្តទៅធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ប៊ុនសុជា រួចកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] សុខគាង ភេទ ប្រុស អាយុ ១៧ ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចលេខ ៥០៣ ចុះថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០២៣ រួចហើយ ។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខគាង បានឆ្លើយថា ខ្លួនពិតជាបានលួចឥវ៉ាន់ពីតូបឈ្មោះ ណារី និងតូបឈ្មោះ [redacted] សារីម ពិតប្រាកដមែន ។ ខ្លួនទើបតែបានលួចចំនួន ពីរដងតែប៉ុណ្ណោះ ដោយលើកទី១ នៅមុនចូលឆ្នាំ និងលើកទី២ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ។ ចំពោះឥវ៉ាន់ដែលខ្លួនបានលួចភាគច្រើនជា ទឹកដោះគោ បារី ខាវ៉ាប៉ាវ ថង់ និងស្លាបព្រា ។ចំពោះឥវ៉ាន់ដែលលួចបាន ខ្លួនបានយកទៅដាក់ជិតផ្ទះឈ្មោះ [redacted] ប៊ុនសុជា ហើយខ្លួនបានសូមអង្វរគាត់អោយគាត់ជួយទិញ ។ ចំពោះការលួចទាំងពីរលើក ខ្លួនលក់បានសរុបចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ។ ខ្លួនព្រមទទួលស្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយហេតុថាខ្លួនរស់



Scanned with CamScanner

នៅតាមសំយ៉ាបផ្ទះគេ គ្មានទីពឹងនោះទេ ទើបខ្លួនសំរេចចិត្តប្រព្រឹត្តដូច្នេះ ដើម្បីបានលុយទិញបាយហូប ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា បានឆ្លើយថា កន្លងមក ឈ្មោះ [redacted] សុខគាង នៅដេកមុខសំយ៉ាបផ្ទះរបស់ខ្លួន ដោយគ្មាគ្មានផ្ទះសំបែង។ នៅអំឡុងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ នេះ ឈ្មោះ [redacted] សុខគាង បានយកថង់ចំនួន ពីរការ៉ុង និងស្លាបព្រា និងចង្កឹះ ទុកនៅកៀនផ្ទះរបស់ខ្លួន ពេលខ្លួនសួរគាត់ គាត់បានប្រាប់ថាយកពីក្នុងផ្សារ ។ នៅពេលនោះឈ្មោះ [redacted] សុខគាង បានអង្វរខ្លួនឱ្យជួយទិញក្នុងតម្លៃ ៥០.០០០ (ប្រាំម៉ឺន) រៀល ខ្លួនពុំដឹងថាឥវ៉ាន់ដែលខ្លួនទិញពីឈ្មោះ [redacted] សុខគាង ជាផលនៃចោរកម្មទេ ។

-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារី បានឆ្លើយថា៖ ខ្លួនជាអាជីវករលក់ចាប់ហួយនៅផ្សារពន្លៃ ស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង ។ នៅអំឡុងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ខ្លួននិងឈ្មោះ [redacted] ផល្លី រួមទាំងឈ្មោះ [redacted] ម៉ាលី ត្រូវជាបងប្អូន បានចេញពីផ្ទះទៅផ្សារពន្លៃ ដើម្បីចាំឃ្លាំមើលតូបលក់ដូររបស់ខ្លួននៅផ្សារ ដោយហេតុថា កន្លងមក ខ្លួនបានបាត់ឥវ៉ាន់ និងខូចខាតសម្ភារៈជាច្រើននៅក្នុងតូប ។ ពេលខ្លួននិងប្អូនមកដល់ផ្ទះផ្សារពន្លៃស្រាប់តែមានឈ្មោះ [redacted] សុខគាង ឈរនៅជិតតូប របស់ឈ្មោះ [redacted] ហា ស្រែកហៅបក្សពួករបស់វាផ្សេងទៀតថា (មកឯងមកយកមក)។ ពេលនោះខ្លួននិងបងប្អូនក៏បានចូលទៅក្នុងផ្សារ ឈ្មោះ [redacted] សុខគាង បានឃើញពួកខ្លួនក៏បានរត់គេចបាត់ស្រមោល។ ខ្លួនបានឆែកកាម៉ារ៉ាសុវត្ថិភាពចាប់រូបភាពឈ្មោះ [redacted] សុខគាង កំពុងកាច់ប្ដូរទិសកាម៉ារ៉ាសុវត្ថិភាពចេញពីកន្លែងដើម តែចំពោះឥវ៉ាន់នៅក្នុងតូបខ្លួន ពុំបានបាត់នោះទេ នាពេលយប់នោះ ដោយខ្លួនមកទាន់ ។ ខ្លួនសូមទាមទារសំណងថ្លៃខូចខាតចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

-តាមអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម បានឆ្លើយថា៖ ខ្លួនជាអាជីវករលក់ចាប់ហួយនៅផ្សារពន្លៃ ស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង ។ នៅអំឡុងថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០២៣ ខ្លួននិងប្រពន្ធឈ្មោះ [redacted] គាលី បានមកដល់តូបនៅផ្សារពន្លៃ ស្រាប់តែឃើញតូបមានសភាព រ៉ាយប៉ាយ ខុសពីធម្មតា ។ ពេលខ្លួនពិនិត្យមើលទៅ ខ្លួនបានបាត់របស់របរដូចជា ថង់ ចំនួន ៦ការ៉ុង ,ចង្កឹះឈើ ,ស្លាបព្រា ,ម៉្យៅដំណើប ចំនួន ២កេស សរុបជាទឹកប្រាក់ចំនួន ១.៥០០.០០០ (មួយលានហាសិបម៉ឺន) រៀល តែខ្លួនមិនដឹងច្បាស់ថាអ្នកណាលួចនោះទេ។ ខ្លួនសុំទាមទារសំណងចំនួន ១.០០០.០០០ (មួយលាន) រៀល ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើស លួច និងទទួលផលចោរកម្ម ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការមិនមានអ្វីសន្និដ្ឋានក្រៅពីតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧១ ដ.ស.ព/២៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការមេត្តាពិនិត្យ និងសម្រេចផ្ដន្ទាទោសលើជនជាប់ចោទ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខគាង បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលជនជាប់ចោទ នៅក្នុងអង្គសវនាការ ឃើញថា កូនក្ដីខ្ញុំបាទបានសារភាពថា ខ្លួនពិតជាបានលួចឥវ៉ាន់ក្នុងតូបពិតមែន តែខ្លួនមិនបានគាស់យកឥវ៉ាន់ទេ គឺបានផ្លោះចូលយកឥវ៉ាន់ពិតមែន។ នៅក្នុងរឿងហេតុនេះ ខ្ញុំបាទសំណូមពរ សុំឱ្យតុលាការមេត្តាសម្រេចផ្ដល់ស្ថានសម្រាលដល់កូនក្ដីខ្ញុំបាទ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលជនជាប់ចោទ នៅក្នុងអង្គសវនាការ ឃើញថា កូនក្ដីខ្ញុំបាទ មិនបានដឹងថាឥវ៉ាន់នោះជារបស់ចោរទេ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ [redacted] សុខគាង មកសុំអង្វរឱ្យកូនក្ដីខ្ញុំបាទជួយទិញ ការដែលកូនក្ដីខ្លួនជួយទិញគឺដើម្បីសម្រាលបន្ទុកចំណាយរបស់អ្នកលក់ប៉ុណ្ណោះ។ នៅក្នុងរឿងហេតុនេះ ខ្ញុំបាទសំណូមពរសុំ



Scanned with CamScanner

ឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទចោទ ។

-ជនជាប់ចោទឈ្មោះ [redacted] សុខគាង បាននិយាយសំដីចុងក្រោយថា ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយនិងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់រួចហើយ

**យល់ឃើញថា÷**

១-ជនជាប់ចោទឈ្មោះ [redacted] សុខគាង ភេទប្រុស អាយុ ១៧ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ **អំពើលួច** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ និងថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] ប៊ុនសុជា ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខគាង បានឆ្លើយថា៖ ខ្លួនពិតជាបានលួចឥវ៉ាន់ពីតូបឈ្មោះ ណារី និងតូបឈ្មោះ [redacted] សារីម ពិតប្រាកដមែន ។ ខ្លួនទើបតែបានលួចចំនួន ពីរដងតែប៉ុណ្ណោះ ដោយលើកទី១ នៅមុនចូលឆ្នាំ និងលើកទី២ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ។ ចំពោះឥវ៉ាន់ដែលខ្លួនបានលួចភាគច្រើនជា ទឹកដោះគោ បារី ខាវ៉ាប៉ាវ ថង់ និងស្លាបព្រា ។ចំពោះឥវ៉ាន់ដែលលួចបាន ខ្លួនបានយកទៅដាក់ជិតផ្ទះឈ្មោះ [redacted] ប៊ុនសុជា ហើយខ្លួនបានសូមអង្វរគាត់អោយគាត់ជួយទិញ ។ ចំពោះការលួចទាំងពីរលើក ខ្លួនលក់បានសរុបចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ។ ខ្លួនព្រមទទួលស្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយហេតុថាខ្លួនរស់នៅតាមសំយ៉ាបផ្ទះគេ គ្មានទីពឹងនោះទេ ទើបខ្លួនសំរេចចិត្តប្រព្រឹត្តដូច្នេះ ដើម្បីបានលុយទិញបាយហូប ។ ចម្លើយនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៤-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា បានឆ្លើយថា កន្លងមកឈ្មោះ [redacted] សុខគាង នៅដេកមុខសំយ៉ាបផ្ទះរបស់ខ្លួន ដោយគ្មាគ្មានផ្ទះសំបែង។ នៅអំឡុងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ នេះ ឈ្មោះ [redacted] សុខគាង បានយកថង់ចំនួន ពីរការ៉ុង ស្លាបព្រា និងចង្កឹះ ទុកនៅកៀនផ្ទះរបស់ខ្លួន ពេលខ្លួនសួរគាត់ គាត់បានប្រាប់ថាយកពីក្នុងផ្សារ ។ នៅពេលនោះឈ្មោះ [redacted] សុខគាង បានអង្វរខ្លួនឱ្យជួយទិញក្នុងតម្លៃ ៥០.០០០ (ប្រាំម៉ឺន) រៀលខ្លួនពុំដឹងថាឥវ៉ាន់ដែលខ្លួនទិញពីឈ្មោះ [redacted] សុខគាង ជាផលនៃចោរកម្មទេ ។ ចម្លើយនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៥-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារី បានឆ្លើយថា៖ ខ្លួនជាអាជីវករលក់ចាប់ហួយនៅ



Scanned with CamScanner

ផ្សារពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ នៅអំឡុងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ខ្លួននិងឈ្មោះ [redacted] ផល្លី រួមទាំងឈ្មោះ [redacted] ម៉ាលី ត្រូវជាបងប្អូន បានចេញពីផ្ទះទៅផ្សារពន្លៃ ដើម្បីចាំឃ្លាំមើលតូបលក់ដូររបស់ខ្លួននៅផ្សារ ដោយហេតុថា កន្លងមក ខ្លួនបានបាត់ឥវ៉ាន់ និងខូចខាតសម្ភារៈជាច្រើននៅក្នុងតូប ។ ពេលខ្លួននិងប្អូនមកដល់ផ្ទះផ្សារពន្លៃស្រាប់តែមានឈ្មោះ [redacted] សុខគាង ឈរនៅជិតតូប របស់ឈ្មោះ [redacted] ហា ស្រែកហៅបក្សពួករបស់វាផ្សេងទៀតថា (មកឯងមកយកមក) ។ ពេលនោះខ្លួន និងបងប្អូនក៏បានចូលទៅក្នុងផ្សារ ឈ្មោះ [redacted] សុខគាង បានឃើញពួកខ្លួនក៏បានរត់គេចបាត់ស្រមោល ។ ខ្លួនបានឆែកកាម៉ារ៉ាសុវត្ថិភាពចាប់រូបភាពឈ្មោះ [redacted] សុខគាង កំពុងកាច់ប្លូរទិស កាម៉ារ៉ា សុវត្ថិភាព ចេញពីកន្លែងដើម តែចំពោះឥវ៉ាន់នៅក្នុងតូបខ្លួន ពុំបានបាត់នោះទេ នាពេលយប់នោះ ដោយខ្លួនមកទាន់។ ខ្លួនសូមទាមទារសំណងថ្លៃខូចខាតចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក។ ចម្លើយនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៦-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម បានឆ្លើយថា៖ ខ្លួនជាអាជីវករលក់ចាប់ហួយនៅផ្សារពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ នៅអំឡុងថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០២៣ ខ្លួននិងប្រពន្ធឈ្មោះ [redacted] គាលី បានមកដល់តូបនៅផ្សារពន្លៃ ស្រាប់តែឃើញតូបមានសភាព រ៉ាយប៉ាយ ខុសពីធម្មតា។ ពេលខ្លួនពិនិត្យមើលទៅ ខ្លួនបានបាត់របស់របរដូចជា ថង់ ចំនួន ៦ការ៉ុង , ចង្កឹះឈើ ,ស្លាបព្រា ,ម៉្សៅដំណើប ចំនួន ២កេស សរុបជាទឹកប្រាក់ចំនួន ១.៥០០.០០០ (មួយលានហាសិបម៉ឺន) រៀល តែខ្លួនមិនដឹងច្បាស់ថាអ្នកណាលួចនោះទេ ។ ខ្លួនសុំទាមទារសំណងចំនួន ១.០០០.០០០ (មួយលាន)រៀល។ ចម្លើយនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាតាមច្បាប់។

៧-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើស លួច និង ទទួលផលចោរកម្ម ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការមិនមានអ្វីសន្និដ្ឋានក្រៅពីតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧១ ជ.ស.ព/២៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការមេត្តាពិនិត្យ និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទ។ សេចក្តីសន្និដ្ឋាន និងការប្តឹងសុំនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា ។

៨-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខគាង បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលជនជាប់ចោទ នៅក្នុងអង្គសវនាការ ឃើញថា កូនក្តីខ្ញុំបាទបានសារភាពថា ខ្លួនពិតជាបានលួចឥវ៉ាន់ក្នុងតូបពិតមែន តែខ្លួនមិនបានគាស់យកឥវ៉ាន់ទេ គឺបានផ្លោះចូលយកឥវ៉ាន់ពិតមែន។ នៅក្នុងរឿងហេតុនេះ ខ្ញុំបាទសំណូមពរសុំឱ្យតុលាការមេត្តាសម្រេចផ្តល់ស្ថានសម្រាលដល់កូនក្តីខ្ញុំបាទ។ សេចក្តីសន្និដ្ឋាន និងការប្តឹងសុំនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា ។

៩-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលជនជាប់ចោទ នៅក្នុងអង្គសវនាការ ឃើញថា កូនក្តីខ្ញុំបាទ មិនបានដឹងថាឥវ៉ាន់នោះជារបស់ចោរទេ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ [redacted] សុខគាង មកសុំអង្វរឱ្យកូនក្តីខ្ញុំបាទជួយទិញ ការដែលកូនក្តីខ្លួនជួយទិញ គឺដើម្បីសម្រាលបន្ទុកចំណាយរបស់អ្នកលក់ប៉ុណ្ណោះ។ នៅក្នុងរឿងហេតុនេះ ខ្ញុំបាទសំណូមពរសុំឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតពីបទចោទ ។ សេចក្តីសន្និដ្ឋាន និងការប្តឹងសុំនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា ។

១០-ជនជាប់ចោទឈ្មោះ [redacted] សុខគាង បាននិយាយសំដីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការលើកលែងទោសឱ្យខ្លួនផង ។ ការសំណូមពរនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។



Scanned with CamScanner

១១-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុខគាង ត្រូវបានច្បាប់កំណត់ជាបទល្មើស **អំពើលួច** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ និងថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១២-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា ត្រូវបានច្បាប់កំណត់ជាបទល្មើស **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

១៣-ផ្អែកតាមចម្លើយនិងអំណានចម្លើយរបស់ជនជាប់ចោទ,ចម្លើយនិងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ , សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ ,របាយការណ៍ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌,ឯកសារនិងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខគាង បានឆ្លើយសារភាពថា ខ្លួនពិតជាបានចូលលួចឥវ៉ាន់នៅក្នុងតូបរបស់ដើមបណ្តឹងឈ្មោះ [redacted]ណារី និងឈ្មោះ[redacted]សារឹម ចំនួន ពីរលើក ពិតប្រាកដមែន ហើយបានយកឥវ៉ាន់ដែលបានលួចនោះ យកទៅសុំអង្វរឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា ជួយទិញក្នុងតម្លៃ ៥០.០០០ (ប្រាំម៉ឺន)រៀល។ ចម្លើយនេះស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម ដែលបានឆ្លើយថា ខ្លួនបានទៅតូបនៅផ្សារពន្លៃ ហើយបានពិនិត្យមើលឃើញឥវ៉ាន់នៅក្នុងតូប មានសភាពរ៉ាយប៉ាយ និងបានបាត់របស់របរដូចជា ថង់ ចំនួន ៦ការ៉ុង , ចង្កឹះឈើ ,ស្លាបព្រា ,ម្សៅដំណើប ចំនួន ២កេស សរុបជាទឹកប្រាក់ចំនួន ១.៥០០.០០០ (មួយលានហាសិបម៉ឺន) រៀល ។ តាមចម្លើយ និងសកម្មភាពខាងលើ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុខគាង ភេទប្រុស អាយុ ១៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួច ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិ ពន្លៃ ឃុំ ពន្លៃ ស្រុក បរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។ រីឯជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា ភេទស្រី អាយុ ៣៩ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

១៤-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខគាង ភេទ ប្រុស អាយុ ១៧ ឆ្នាំ ជនជាតិ ខ្មែរ ពីបទ លួច ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិ ពន្លៃ ឃុំ ពន្លៃ ស្រុក បរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១៥-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា ភេទស្រី អាយុ ៣៩ឆ្នាំ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

១៦-តាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម ។ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនប្តឹងតវ៉ា និងទូទាត់សំណងរួចហើយ គប្បីតុលាការមិនពិចារណាអំពីសំណងរដ្ឋប្បវេណីនេះទៀតទេ ។



Scanned with CamScanner

**ហេតុដូច្នេះតុលាការ**
**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខគាង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ) ឆ្នាំ ពីបទ៖ លួច ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំ ពន្លៃ ស្រុក បរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០២ (ពីរ) ឆ្នាំ ប៉ុន្តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា តាមមាត្រា ១០៤ មាត្រា ១០៦ មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចផ្សារពន្លៃ ស្ថិតក្នុងភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សុខគាង សងសំណងនៃថ្លៃបាត់បង់ជាប្រាក់ចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល និងសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារី ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខគាង និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារី, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុជា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កំពង់ឆ្នាំង, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៤

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

"**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**"
ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កំពង់ឆ្នាំង, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៤

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner